Australian Government

Job Services Australia
people • skills • jobs

# Work Experience: Unpaid Work Experience

ការដាក់ឲ្យធ្វើការងារដើម្បីយកបទពិសោធន៍ដោយគ្មានកម្រៃ (Unpaid Work Experience Placement) ជាការ ដាក់ឲ្យធ្វើការងារស្ម័គ្រ ចិត្តជាមួយអង្គការផ្តល់ការងារ ដែលហុចនូវឱកាសឱ្យលោកអ្នកទទួលបានជំនាញវិជ្ជាជីវៈជាក់លាក់ និងបទពិសោធន៍ពីមជ្ឍដ្ឋានការងារ។

Unpaid Work Experience អាចផ្តល់ការងារក្នុងឧស្សាហកម្ម ឬអង្គការជាក់លាក់ណាមួយ ដែលអាចពុំមានជូនតាមរយៈសកម្មភាព Work Experience ដទៃទៀត មានដូចជា Work for the Dole ជាដើម។ ការផ្តល់ការងារអាចមានរយៈពេលរហូតដល់ទៅ៤សប្តាហ៍។

Unpaid Work Experience Placement គឺមិនមែនជាការផ្តល់ការងារកន្លែងបណ្តុះបណ្តាលហ្វឹកហ្វឺន ឬក៏ការបង្ហាត់ជំនាញនោះឡើយ ហើយសកម្មភាពនេះគួរតែធ្វើឡើង តែនៅពេលណា ដែលមើលទៅទំនងជាហុចនូវលទ្ធផលផ្តល់នូវការងារដែលមានកម្រៃនឹងនប៉ុណ្ណោះ។

## តើអ្នកណាអាចចូលរួមបាន?

លោកអ្នកអាចទទួល Unpaid Work Experience Placement បាន លុះត្រា តែលោកអ្នកចូលរួមដោយស្ម័គ្រ ចិត្ត។

Unpaid Work Experience Placement មានសម្រាប់អ្នកស្វែងរកការងារដែលមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅ និងអ្នកដែល ៖

- ចូលរួមក្នុងដំណាក់កាលដកបទពិសោធន៍ការងារពីសេវាមួយចំនួន (Work Experience Phase of Stream Services) ឬ
- អ្នកស្វែងរកការងារក្នុងបណ្តាញរកការងារសម្រាប់ជនពិការ (Disability Employment Network) ឬសេវាស្តារនីតិសម្បទាវិជ្ជាជីវៈ (Vocational Rehabilitation Service)។

ស្ថាប័នផ្តល់សេវាការងារអូស្ត្រា លី (Job Services Australia) សមាជិក Disability Employment Network ឬស្ថាប័នផ្តល់ Vocational Rehabilitation Service នឹងមានលទ្ធភាពផ្តល់ការណែនាំថាតើលោកអ្នកមានសិទ្ធិទទួល Unpaid Work Experience Placement ឬយ៉ាងណានោះ។

## របៀបដាក់ពាក្យសុំ

ប្រ សិនបើលោកអ្នកមានចំណាប់អារម្មណ៍ចំពោះ Unpaid Work Experience Placement លោកអ្នកគួរពិភាក្សាអំពីចំណាប់អារម្មណ៍នេះជាមួយស្ថាប័ន Job Services Australia សមាជិក Disability Employment Network ឬស្ថាប័នផ្តល់ Vocational Rehabilitation Service។

## ភាតព្វកិច្ចរបស់លោកអ្នក

ប្រ សិនបើលោកអ្នកទទួល Newstart , ប្រាក់ឧបត្ថម្ភយុវជន (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ដោយមានការតម្រូវឲ្យចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារ ហើយចូលរួមក្នុងសកម្មភាព ដែលនឹងជួយឱ្យលោកអ្នកបានទទួលការងារធ្វើ។

ស្ថាប័នផ្តល់ Job Services Australia នឹងពិចារណាអំពីស្ថានភាពរបស់លោកអ្នកផ្ទាល់ ហើយចរចាអំពីសកម្មភាពសមរម្យ ដើម្បីដាក់បញ្ចូលក្នុងផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។

ប្រ សិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនេះបានទេ លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់សេវារបស់លោកអ្នក។ ប្រ សិនបើលោកអ្នកខកខានមិនបានអនុវត្តសកម្មភាពដែលបានព្រ មព្រៀងនោះ ការខកខាននេះអាចប៉ះពាល់ដល់ប្រាក់ជំនួយទ្រ ទ្រង់ប្រាក់ចំណូលរបស់លោកអ្នក។

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយ ព័ត៌មានអំពីលោកអ្នកអាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រ សិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រ ទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia សមាជិក Disability Employment Network ស្ថាប័ន Vocational Rehabilitation Service ព្រ មទាំងក្រ សួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR] (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រា ស់រួមគ្នា ជាមួយ Centrelink និងក្រ សួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រា លីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្រ បបំផុតដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័ន Job Services Australia សមាជិក Disability Employment Network ស្ថាប័ន Vocational Rehabilitation Service, DEEWR ឬបើកមើលវិបសាយថ៍ **privacy.gov.au** ។

7FS09446JSA/khmer

# ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

## ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

## ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្រ្តាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

# សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia។**